មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

២៣-៨-២០០៦ -ព្រះរាជក្រម នស/រកម/០៨០៦/០២២ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពី វិសោធនកម្មមាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ៦០៦៨

២៣-៨-២០០៦ -ព្រះរាជក្រម នស/រកម/០៨០៦/០២៣ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស៊ីណូហាយដ្រូ ខបផរ៉េហ្សិន លីមីតធីត ៦០៧២

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការបង្កើត គណៈកម្មាធិការជាតិ លើកកំពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ៦០៩១

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៩៦

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៩៧

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៩៩

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១០០

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១០១

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១០២

២៤-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៦១០៣

២៤-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពីការបង្កើតថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ៦១០៤

២៥-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៦១០៦

២៥-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦១០៧

២៥-៨-២០០៦ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសម្រាប់សភាពាណិជ្ជកម្មខេត្តកណ្តាល អាណត្តិទី ១ លើកទី ១ ៦១០៨

២៥-៨-២០០៦ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មខេត្តតាកែវ អាណត្តិទី ១ លើកទី ១ ៦១១១

២-ប្រកាស

២៤-៨-២០០៦ -ប្រកាសលេខ ០១ ប្រក ស្តីពីការកំណត់បែងចែកភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក ៦១១៤

៣-បទបញ្ជា

១០-៥-២០០៦ -បទបញ្ជាលេខ ០១ បប ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ ៦១១៦

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ុំ សេង ខូ អិលធីឌី** ៦១១៧

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេម្រ៉ាំខន គ្រុប** ៦១១៩

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៃ យូ (ខេមបូឌា)** ៦១២១

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ិក គ្រុប ខូ អិលធីឌី** ៦១២៣

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថ្រាយ ដាយអឺម៉ិន** ៦១២៥

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆ្វិតល ស៊ី គ្រុប** ៦១២៧

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដេឌីល** ៦១២៩

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីវ៉យ (ខេមបូឌា) អ៊ិនធើណេសិនណល** ៦១៣១

០៣-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៦៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គេត ឌ៉ាក់ឌី ខូ អិលធីឌី**	៦១៣៣
០៣-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វត្លូអិនស៍ ខ្មែរ អ៊ិនធើណេសិនណល អ៊ិនវេស ឌីវេឡុប អហ្វ ប្លុក**	៦១៣៥
០៣-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ស៊ី អ ស៊ី អ៊ីមផត អិចផត**	៦១៣៧
០៣-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធីន ប្រូដាក់សិន**	៦១៣៩
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អែសូមិ គ្រុប ខូ អិលធីឌី**	៦១៤១
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អូ អិម ឡូជីស្ទិក ខប**	៦១៤៣
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វើលវ៉ាយដ៍ ដេលីវើរី (ខេមបូឌា) ខូ អិលធីឌី**	៦១៤៥
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភាណាតិច ខមភេនី អិលឌីឌី**	៦១៤៦
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តិរក្ខ អេឡិកត្រូនិក (ខេមបូឌា)**	៦១៤៨
០៤-៧-២០០៦	-លិខិតបញ្ជាក់លេខ ១៦៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី ឌី ឌី ខេម**	៦១៥០

នស/រកម/០៨០៦/០២៧

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ នៃច្បាប់ស្ដីពីសភាពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

២

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ២ និងមាត្រា ១៥
នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម

មាត្រាតែមួយ.-

មាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ត្រូវបានកែប្រែដូចតទៅ :

មាត្រា ២ ថ្មី.-

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនីមួយៗ ត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភាពាណិជ្ជកម្មនោះ ។

សភាពាណិជ្ជកម្មខេត្ត ក្រុង ប្រមូលផ្តុំបង្កើតជាសភាពាណិជ្ជកម្មថ្នាក់ជាតិមួយឈ្មោះហៅថា សភាពាណិជ្ជកម្មកម្ពុជា ដែលធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅព្រមទាំងភារកិច្ចរបស់សភាពាណិជ្ជកម្មកម្ពុជានឹងត្រូវកំណត់

ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា១៥ ថ្មី .–

ចំណាយសម្រាប់ការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ត្រូវផ្គត់ផ្គង់ដោយ :

-វិភាគទានរបស់សមាជិក

-អំណោយក្នុងនិងក្រៅប្រទេស

-ចំណូលមកពីការគ្រប់គ្រងគ្រឹះស្ថាន និងការចេញថ្ងៃនានា

-ចំណូលព្រមទាំងវិភាគទានមកពីប្រភពផ្សេងៗ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រស.០៧០៤.៣៤៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

លេខ : ៣៤៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកម/០៨០៦/០២៣

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម លើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនស៊ុណ្ហូហាយដ្រូ ឧបផវើហ្សិន លីមីតធីត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស៊ីណូហាយដ្រូ ខបផរ៉េហ្សិន លីមីតធីត

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនិងក្រុមហ៊ុនអគ្គិសនីកម្ពុជាឱ្យក្រុមហ៊ុនស៊ីណូហាយដ្រូ ខបផរ៉េហ្សិន លីមីតធីត ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនស៊ីណូហាយដ្រូខបផរ៉េហ្សិន លីមីតធីត និងកិច្ចព្រមព្រៀងទិញ-លក់ អគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុនស៊ីណូហាយដ្រូ ខបផរ៉េហ្សិន លីមីតធីត ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៦ ដោយរដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតជានាទូទាត់នេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៦០៨.៣៨៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

ស៊ុយ សែម

លេខ : ៣៨៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៨ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យន្ត ហឹនកេន

ឃល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១.....សហវ.ប្រក

ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៦

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ : **លោក លីម គីតាង**

ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន ស៊ីណូហាយដ្រូ ខមផូរេហ្សិន លីមីធីធី

ផ្ទះលេខ ១, Ertiao ផ្លូវ Bai Guang, ស្រុក Xuan Wu,

ទីក្រុងប៉េកាំង ១០០៧៦១ សាធារណរដ្ឋប្រជាមានិតចិន

យោង :

(ក) **សិទ្ធិប្រទាន** លេខ ៧៨. សប្រទ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ដោយ **សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃរាជរដ្ឋាភិបាលកម្ពុជា ។ (ភ្ជាប់មកជាមួយនូវលិខិតសិទ្ធិប្រទាន ក្នុងឧបសម្ព័ន្ធ១)

(ខ) **កិច្ចព្រមព្រៀងអនុវត្តគំរោង** ("IA") ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៦ ដែលបានចុះហត្ថលេខារវាង **រាជរដ្ឋាភិបាលកម្ពុជា** ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** និង "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ ខមផូរេហ្សិន លីមីធីធី**" ។

(គ) **អគ្គិសនីកម្ពុជា (អក)** ជាសហគ្រាសរដ្ឋ ដែលមានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ <u>ជលស/រកត/០៣៩៦/១០</u> ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួនតាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ **(អក)** ដែលបានចុះកិច្ចព្រមព្រៀងទិញលក់អគ្គិសនីជាមួយ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** យល់ព្រមផ្តល់ : (១)-ការធានាការទូទាត់ក្នុងការទិញថាមពលអគ្គិសនីក្នុងករណីដែល **អគ្គិសនីកម្ពុជា** មិនធ្វើការទូទាត់ និង (២)-ការធានាទិញមធ្យោបាយគំរោងដោយបញ្ចប់កិច្ចព្រមព្រៀង ស្របតាម **កិច្ចព្រមព្រៀង ទិញលក់អគ្គិសនី** និង/ឬ **កិច្ចព្រមព្រៀងអនុវត្តគំរោង** និង ក្នុងករណីដែល "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" មិនអាចដំណើរការមធ្យោបាយអគ្គិសនីបាន ដោយកើតចេញពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ ។

(ង) តាមការតម្រូវក្នុងមាត្រា ៩.១ នៃកិច្ចព្រមព្រៀងអនុវត្តគំរោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា (**អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាការទូទាត់របស់ "**អក**"/"**ក្រ ខ្ញ រ៉ ថ**" ស្របតាម កិច្ចព្រមព្រៀងទិញលក់អគ្គិសនី និងកិច្ចព្រមព្រៀងអនុវត្តគំរោង ។

ដូច្នេះយើងខ្ញុំសូមធានា ថា :

២. "**អ្នកធានា**" ធានានិងសន្យាដោយគ្មានល័ក្ខខ័ណ្ឌ និងដោយគ្មានការបដិសេធទូទាត់ឱ្យ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ដែលត្រូវបង់ និងជំពាក់ដោយ "**ក្រ ខ្ញ រ៉ ថ**" ឬ "**អក**" ឱ្យ "ក្រុមហ៊ុន **ស៊ីណូហាយដ្រូ**" ស្របតាមកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនីដែល "**ក្រ ខ្ញ រ៉ ថ**" ឬ "**អក**" ខកខានពុំបានទូទាត់អនុលោមតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬ កិច្ចព្រមព្រៀងទិញលក់អគ្គិសនី ។

២. លិខិតធានានេះត្រូវជាការធានាថា បន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" គ្រប់ពេលដោយ "**ក្រ ខ្ញ រ៉ ថ**" ឬ "**អក**" ស្របតាមកិច្ចព្រមព្រៀងអនុវត្តគំរោង ឬកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬ អសមត្ថភាព ឬ ការផ្លាស់ប្តូរណាមួយក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង "**ក្រ ខ្ញ រ៉ ថ**" ឬ "**អក**" ឬ ក្នុងនាម ឬ របៀប ឬ ការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់អនុវត្តលិខិតធានានេះ និងតម្រូវការការទូទាត់ពី **អ្នកធានា**, "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរសំរាប់ការទូទាត់ពី "**ក្រ ខ្ញ រ៉ ថ**" ឬ "**អក**" ។ ក្រោយទទួលវិក្កយបត្រ ៦០ (ហុកសិប)ថ្ងៃ ដូចបានចែងក្នុងមាត្រា ៨.៧.១ នៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬ សំណើទូទាត់ណាមួយពី "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ទៅ

"ក្រ ខ្ញ រ ៩ " ឬ "អគ " "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " អាចជូនដំណឹងទៅ **អ្នកធានា** ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ "ក្រ ខ្ញ រ ៩ " ឬ "អគ " បានហួសកាលកំណត់ និងលើកសំណើទូទាត់ពី **អ្នកធានា** ស្របតាមលិខិតធានានេះ ហើយ **អ្នកធានា** ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ។ ការយឺតយ៉ាវក្នុងការទូទាត់របស់ **អ្នកធានា** ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូកនិង ៣% (បីភាគរយ) ។ ហើយពុំមានសំណើណាដែលបានធ្វើឡើងដោយ "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬដំទាស់សិទ្ធិរបស់ "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " ក្នុងករណីសំណើបន្ថែម ឬ ផ្សេងទៀត ចំពោះវិក័យបត្រមិនបានទូទាត់ផ្សេងទៀត ។

ទឹកប្រាក់ទាំងអស់ដែល **អ្នកធានា** ត្រូវទូទាត់ឱ្យតាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែល "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " បានកំណត់ជាដុល្លាអាមេរិកឱ្យ "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " ។

៤. រាល់ការធ្វើសំណើទូទាត់ណាមួយ ដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬតាមរយៈបុគ្គលដែលជាមន្ត្រី ទទួលបានការអនុញ្ញាតស្របច្បាប់របស់ "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " នៅការិយាល័យរបស់ **អ្នកធានា** និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ "**ក្រុមហ៊ុន ស៊ុណ្ហហាយរដ្ឋ** " (ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត) ដោយបញ្ជាក់ថា :

(ភ្ជាប់មកជាមួយនូវគំរូលិខិតសំណើទូទាត់ពីអ្នកធានា ឧបសម្ព័ន្ធ ២)

៥. **អ្នកធានាសូមអះអាង និងធានា** នៅថ្ងៃនេះថា :

អ្នកធានា មានសិទ្ធិអំណាច និងការអនុញ្ញាតស្របច្បាប់ដើម្បីអនុវត្ត និងប្រគល់ ព្រមទាំងប្រតិបត្តិតាមល័ក្ខខ័ណ្ឌនៃលិខិតធានានេះ ។

លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណង ដែល **អ្នកធានា** ត្រូវអនុវត្តអនុលោមតាមល័ក្ខខ័ណ្ឌរបស់វា ។

រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការអនុវត្តន៍ត្រូវបានទទួល ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការអនុវត្តន៍ ការផ្តត់ផ្គង់ និងការប្រតិបត្តិលិខិតធានានេះ ។

កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់ **អ្នកធានា** ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានល័ក្ខខ័ណ្ឌរបស់ **អ្នកធានា** ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សំរាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់ **អ្នកធានា** ។

អ្នកធានា បានយល់ព្រមដោយគ្មានល័ក្ខខ័ណ្ឌ និងដោយគ្មានការបដិសេធថា ការអនុវត្តន៍ និងការផ្តល់ជូនដោយ **អ្នកធានា** តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពជាសាធារណៈ ឬ ជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានល័ក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។

ប្រសិនបើមានបណ្តឹងណាមួយចំពោះ **អ្នកធានា** ឬចំពោះទ្រព្យសម្បត្តិរបស់គេ ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ មិនមានអភ័យឯកសិទ្ធិណាពីបណ្តឹងត្រូវបានទាមទារដោយ ឬ តាងនាមរបស់ខ្លួន ឬ ទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់គេ ដែលមានបច្ចុប្បន្ន ឬ អាចទទួលបាននាពេលអនាគត ។

៦. លិខិតធានាត្រូវមានសុពលភាព និង ប្រសិទ្ធភាពចាប់ពីថ្ងៃចាប់ផ្តើមដំណើរការសាងសង់រហូតដល់បញ្ចប់អាណត្តិនៃកិច្ចព្រមព្រៀងអនុវត្តគំរោង ឬ កិច្ចព្រមព្រៀងទិញលក់អគ្គិសនី និងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយដែល "អក" ជំពាក់ "**ក្រុមហ៊ុន ស៊ុណ្ណូហាយដ្រូ**" ទាក់ទងនឹងល័ក្ខខ័ណ្ឌ ឬ នៅពុំទាន់សង ។ ប៉ុន្តែទោះបីយ៉ាងណា ក្នុងករណីនៃ "ការធានាទិញថាមពលក្នុងករណីដែលអគ្គិសនីកម្ពុជាពុំបានទូទាត់សំរាប់ថាមពលមូលដ្ឋាន "លិខិតធានានេះត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគំរោង (ដូចដែលបានកំណត់នៅក្នុងទំព័រ៦០ ក្នុងកម្មវិធីទី១ នៃ PPA) ។

៧. មិនយកការខកខាន ឬ ការយឺតយ៉ាវណាឡើយ ដោយ "**ក្រុមហ៊ុន ស៊ុណ្ណូហាយដ្រូ**" ក្នុងការអនុវត្តន៍សិទ្ធិ ឬ ការដោះស្រាយណាមួយក្រោមការធានានេះ ជាការបដិសេធ ឬ ដោះស្រាយឡើយ ។ គ្មានការអនុវត្តន៍នូវសិទ្ធិ ឬ ការដោះស្រាយដោយភាគីមួយ ឬ ការអនុវត្តន៍សិទ្ធិមួយផ្នែក ច្រានចោលការអនុវត្តន៍បន្ថែមផ្សេងទៀត ឬ ការអនុវត្តន៍សិទ្ធិ ឬ ការដោះស្រាយណាមួយផ្សេងទៀត ។ ការបដិសេធរបស់ "**ក្រុមហ៊ុន ស៊ុណ្ណូហាយដ្រូ**" មានប្រសិទ្ធភាព លុះត្រាតែការបដិសេធធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

សិទ្ធិ និងការដោះស្រាយនានាបានផ្តល់ឱ្យ "**ក្រុមហ៊ុន ស៊ុណ្ណូហាយដ្រូ**" ដោយការធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយដែលបានផ្តល់ដោយច្បាប់ ។

៨. រាល់លិខិតជូនដំណឹង ឬ លិខិតឆ្លងឆ្លើយផ្សេងៗទៀត (ដែលបន្ទាប់ពីនេះទៅត្រូវហៅរួមគ្នាថា "**លិខិតជូនដំណឹង**") ដែលត្រូវផ្តល់ឬធ្វើឡើង ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គលដូចខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍ ។ រាល់លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់ជូន :

(ក) ពេលប្រគល់ផ្ទាល់ដៃ ឬ

(ខ) នៅពេលប្រគល់មានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់បញ្ជូនទៅភាគីដែលបានទទួល ទៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដូចជាភាគីនោះអាចកំណត់ដោយលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិតតាមអាសយដ្ឋាន ឬ លេខទូរសារចែងខាងក្រោម) :

អាសយដ្ឋានសំរាប់ផ្ញើលិខិតជូនដំណឹងគឺ :

សំរាប់ **អ្នកធានា** :

ជូនចំពោះ : **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អាសយដ្ឋាន : ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសារលេខ : ៨៥៥-២៣-៤២៧ ៧៩៨

សំរាប់ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" : Sinohydro Corporation Ltd.

ជូនចំពោះ : **សិន ឌីស៊ែ** (យោងលិខិតប្រទានសិទ្ធិលេខ ០៣,២០០៦-shc-០១ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៦)

: នាយកក្រុមហ៊ុន **ស៊ីណូហាយដ្រូ ខបផូរេហ្សិន អិលធីឌី**

អាសយដ្ឋាន : No.1, Ertiao, Bai Guang Road, Xuan Wu District, Beijing 100761, P. R. China

ទូរសារលេខ : ៨៦-១០-៦៣៥៨ ១៧៩៧

ឬក៏ អាសយដ្ឋានផ្សេងទៀតដូចដែលភាគីណាមួយអាចជូនដំណឹងឱ្យភាគីណាមួយ ។

៩. **អ្នកធានា** មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាមុនពី "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" ឡើយ ហើយ "ក្រុមហ៊ុន **ស៊ុណហាយជ្រ្ទ**" មិនត្រូវប្រគល់ ឬ ផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការអនុញ្ញាតជាមុនពី **អ្នកធានា** ឡើយ ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះ សំរាប់គោលបំណងអភិវឌ្ឍន៍ ឬ ផ្តល់ហិរញ្ញប្បទានជារចនាសម្ព័ន្ធ របស់គម្រោង "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" ត្រូវប្រគល់ ឬ បង្កើតការធានាផលប្រយោជន៍ចំពោះសិទ្ធិផលប្រយោជន៍របស់ខ្លួន និងសំរាប់អ្នកឱ្យខ្ចីប្រាក់ ។

លិខិតធានានេះត្រូវជាចំណងផ្លូវច្បាប់ និងមានអត្ថប្រយោជន៍ដល់ **អ្នកធានា** និង "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" ព្រមទាំងអ្នកបន្តវេន្ត និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់ **អ្នកធានា** និង "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" អនុលោមតាមលិខិតធានានេះត្រូវបានគ្រប់គ្រងនិងបកស្រាយតាមច្បាប់ប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តវិនិច្ឆ័យផង ។

ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធទៅនឹងលិខិតធានានេះ ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ **អ្នកធានា** និង "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" ត្រូវសាកល្បងដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព ។ ប្រសិនបើមិនអាចដោះស្រាយ បានតាមរយៈការពិភាក្សាជាមិត្តភាពទេ គេត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើរវាងមាត្រានេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ មាត្រានេះត្រូវមានប្រសិទ្ធភាព ។ សេចក្តីសំរេចត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយគឺជាសេចក្តីសំរេចស្ថាពរ និងមានប្រសិទ្ធភាព ទៅលើ **អ្នកធានា** និង "**ក្រុមហ៊ុន ស៊ុណហាយជ្រ្ទ**" និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសំរេចនេះអនុវត្តបាន ។ ភាគីទាំងនោះត្រូវអនុវត្តសេចក្តីសំរេចនោះ ហើយភាគីនីមួយៗមិនអាចបដិសេធ ដោយឥតប្រកែកបាននូវសិទ្ធិណាមួយដែលគេមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសំរេចនេះ ឬយុត្តាធិការ នៃតុលាការមជ្ឈត្តវិនិច្ឆ័យដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលបានលិខិតធានានេះ ។ ការទូទាត់តាមសេចក្តីសំរេចរបស់មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងជា **ដុល្លារអាមេរិក** ។ ចំណាយលើមជ្ឈត

វិនិច្ឆ័យត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ។ ភាគីដែលទទួលខុសត្រូវការទូទាត់សេចក្តីសំរេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣%(បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសំរេចពីមជ្ឈត្តវិនិច្ឆ័យនោះ ក្នុងកាលបរិច្ឆេទសមស្រប រហូតដល់ថ្ងៃទូទាត់រួច ។

១១. ពាក្យសរសេរជាអក្សរធំដែលប្រើ ប៉ុន្តែពុំមានកំណត់ក្នុងលិខិតធានានេះត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ។

ប្រសិនបើ បញ្ញត្តិមួយ ឬច្រើនដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬ គ្មានតម្លៃតាមផ្លូវច្បាប់ ត្រូវផ្តល់សុពលភាពដល់បញ្ញត្តិតាមផ្លូវច្បាប់ ហើយ អសុពលភាព ភាពខុសច្បាប់ ឬ ភាពគ្មានតម្លៃតាមផ្លូវច្បាប់នៃបញ្ញត្តិនោះ ពុំមានឥទ្ធិពលដល់សុពលភាពនៃបញ្ញត្តិសេសសល់ផ្សេងទៀតនៃលិខិតធានានេះ ។

តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់ ការប្តឹងទាមទារ ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយដែល **អ្នកធានា** មាន ឬអាចមានចំពោះ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ត្រូវតែមានសំរាប់ **អ្នកធានា** ចំពោះ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់ **អ្នកធានា** ចំពោះ "**ក្រុមហ៊ុន ស៊ីណូហាយដ្រូ**" ស្របតាមលិខិតធានានេះ ។

១២. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចព្រមព្រៀងអនុវត្តគំរោង និងកិច្ចព្រមព្រៀងទិញលក់អគ្គិសនីដែរ ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានាតាមនេះដដែល ហេតុដូច្នេះ យើងខ្ញុំត្រូវតែទទួលបានមុនពេលផុតកំណត់នេះ នូវការស្នើសុំជាលាយល័ក្ខអក្សរណាមួយពីលោកមកយើងខ្ញុំពីបញ្ហានេះ ។

សូមលោក មេត្តាទទួលការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី (គសហវ)
- ក្រុមហ៊ុនអគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

រដ្ឋលេខាធិការទី១
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គង់ វិបុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៧៨ . សប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៦

សិទ្ធិប្រទាន

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ប្រគល់សិទ្ធិពេញសមត្ថភាពជូន **ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដើម្បីចុះហត្ថលេខា លើលិខិតធានារបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះការទូទាត់របស់រដ្ឋ (FORM OF GOVERNMENT GUARANTEE OF PAYMENT) ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅអោយក្រុមហ៊ុន Sinohydro Corporation Ltd. ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដោយមានសិទ្ធិពេញលេញក្នុងតំណែងបានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ឧបសម្ព័ន្ធ ២

គំរូលិខិតសំណើទូទាត់ពីអ្នកធានា

យើងខ្ញុំសូមបញ្ជាក់ ថា :

(១) **ក្រុមហ៊ុន ស៊ុណរូហាយដ្រូ** ("**ក្រុមហ៊ុន**") បានធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **(អ្នកធានា)** ក្នុងចំនួនទឹកប្រាក់ .... [បញ្ចូលចំនួនទឹកប្រាក់] ជាដុល្លារអាមេរិក ស្របតាមលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៦ រវាង **អ្នកធានា** និង "**ក្រុមហ៊ុន ស៊ុណរូហាយដ្រូ**" ។

(២) ចំនួនទឹកប្រាក់កំណត់ខាងលើ គឺជាលំពេលត្រូវទូទាត់ដោយ "គ្រ ឱ រ៉ ថ" ឬ "អគ" ស្របតាមកិច្ចព្រមព្រៀងទិញលក់អគ្គិសនី / កិច្ចព្រមព្រៀងអនុវត្តគំរោងរវាង "**ក្រុមហ៊ុន ស៊ុណរូហាយដ្រូ**" និង "គ្រ ឱ រ៉ ថ" / "អគ" និងពុំមានផ្នែកណានៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃជម្លោះរវាង "គ្រ ឱ រ៉ ថ" / "អគ" និង "**ក្រុមហ៊ុន ស៊ុណរូហាយដ្រូ**" ។

(៣) សំណើទូទាត់ពី "គ្រ ឱ រ៉ ថ" / "អគ" ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ "គ្រ ឱ រ៉ ថ" / "អគ" រហូតដល់ថ្ងៃនេះ

ហត្ថលេខា

តំណាង

ស៊ុណរូហាយដ្រូ ខបផូរេហ្សិន លីមីធីត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

N°...001...MEF/..GGP

GOVERNMENT GUARANTEE OF PAYMENTS

Mr. LIU QITAO
CHAIMAN OF THE BOARD
Sinohydro Corporation Ltd.
No.1, Ertiao, Bai Guang Road, Xuan Wu District
Beijing 100761, P.R. China

Phnom Penh, July 4, 2006

Dear Mr. Qitao,

We refer to:

(A) Delegation of Full Powers No. 78 DFP Dated June 30, 2006 by Samdech Hun Sen, Prime Minister of the Royal Government of Cambodia (RGC). **(Please see attachement 1)**

(B) The Implementation Agreement ("IA") dated 23rd February 2006, entered between the Royal Government of Cambodia ("RGC") represented by Minister of the Ministry of Industry, Mines and Energy ("MIME") and Sinohydro corporation Ltd (Sinohydro).

(C) ELECTRICITÉ DU CAMBODGE (EDC), a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Sang Kat Wat Phnom, Khan Daun Penh, Phnom Penh, Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Purchase Agreement ("PPA") with Sinohydro dated February 23, 2006.

(D) The Royal Government of Cambodia agreed to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with PPA and/or IA in the event that Sinohydro is unable to operate the Facility arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.1, the Minister of Economy and Finance ("MEF") on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MIME under the PPA and IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay Sinohydro any and every sum of money which is due and owed by MIME or EDC to

Sinohydro under the IA or PPA that MIME or EDC has failed to pay in accordance with the terms of the PPA and IA.

2 This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to Sinohydro at any time from MIME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, Sinohydro shall be obliged only to make demand in writing for payment from MIME or EDC. After sixty (60) Days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from Sinohydro to MIME being received by EDC or MIME, Sinohydro may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by Sinohydro hereunder shall prejudice or restrict the right of Sinohydro to make further or other demands against any other unpaid invoice(s).

All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by Sinohydro in the Kingdom of Cambodia in US Dollars to Sinohydro.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of Sinohydro at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of Sinohydro stating, without the obligation to substantiate, that: **(Please see attachement 2)**

5. The Guarantor represents and warrants that, as of the date hereof:

The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.

This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.

All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.

The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.

The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.

Should any proceedings be brought against it or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PPA and for so long thereafter as any amount owed to Sinohydro by EDC in connection with such term is or may be outstanding. However, such Guarantee on power purchase in the event of non-payment by EDC for the Base Energy shall be applicable from the Commercial Operation Date (COD, as definition stipulated in Page 60, Schedule 1 of PPA) of the Project.

7. No failure or delay by Sinohydro to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by Sinohydro shall be effective unless it is in writing.

The rights and remedies of Sinohydro provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

(a) When presented personally, or

(b) Upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:
Attention: **H.E Minister of Economy and Finance**
Address: Ministry of Economy and Finance
Street No.92, Sangkat Wat Phnom
Khan Daun Penh, Phnom Penh
Kingdom of Cambodia

Facsimile: 855 23 427798

For Sinohydro: **Sinohydro Corporation Ltd.**

Attention: **Mr. Shen Decai** (Ref power of attorney Ref. No. 03/2006-shc-01 date: March 16, 2006)
Director
Sinohydro Corporation Ltd
Address: No.1, Ertiao, Bai Guang Road, Xuan Wu District,

Beijing 100761, P. R. China
Facsimile: +86 10 63581797

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of Sinohydro, and

Sinohydro shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, Sinohydro may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders.

This Guarantee shall be binding upon and inure to the benefit of the Guarantor and Sinohydro and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and Sinohydro under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and Sinohydro shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and Sinohydro and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

11. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement.

If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against Sinohydro shall be available to

the Guarantor against Sinohydro in connection with any obligation of the Guarantor to Sinohydro under this Guarantee.

12. This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to us by your hereunder must therefore be received by us before that time.

Please accept, Mr. LIU QITAO, the assurances of my high consideration.

Kong Vibol
First Secretary of State
Ministry of Economy and Finance
Acting on behalf of the Royal Government of Cambodia

CC :

- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council of Ministers
- Ministry of Foreign Affairs and International Cooperations
- Ministry of Industry Mine and Energy
- Cabinet of Semdech Prime Minister
- Council for the Development of Cambodia (CDC)
- Cabinet of Senior Minister of MEF
- Electricité du Cambodge (EDC)
- File

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government
N° 78 D.F.P

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

Phnom Penh, June 30 2006

DELEGATION OF FULL POWERS

The Royal Government of Cambodia delegates herewith to H.E. Mr. KONG VIBOL First Secretary of State, Ministry of Economy and Finance, Full Power to sign the FORM OF GOVERNMENT GUARANTEE OF PAYMENT by the EDC to **Sinohydro Corporation Ltd.**

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

HUN SEN

ATTACHMENT : 2

SAMPLE OF CLAIM FORM FOR PAYMENT FROM THE GUARANTOR

Attention to: **H.E Minister of Economy and Finance**
Address: Ministry of Economy and Finance
Street No.92 Sangkat Wat Phnom
Khan Daun Penh, Phnom Penh
Kingdom of Cambodia.

Facsimile: 855 23 427798

"We hereby certify that:

(1) Sinohydro Corporation Ltd is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U. S. Dollars ________[insert amount] in accordance with the Government Guarantee of payment dated July 4, 2006 between the Guarantor and Sinohydro Corporation Ltd.

(2) The amount specified above is due and payable by [EDC or MIME] under the PPA/IA between Sinohydro and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and Sinohydro;

(3) Demand in writing for payment from MIME/EDC has been made;

(4) Such amount, on the date hereof, remains unpaid by MIME/EDC. "

Sincerely yours,

Authorised Representative
SINOHYDRO CORPORATION LTD.

中国水利水电建设集团公司

TO WHOM IT MAY CONCERN:

POWER OF ATTORNEY

Ref. No. 03/2006-SHC-01
Date: Mar. 16, 2006

KNOW ALL MAN BY THESE PRESENTS: that I, the undersigned, **Mr. Liu Qitao**, Chairman of the Board of **Sinohydro Corporation Ltd.**(**Sinohydro** in short), a company duly incorporated under the laws of the People's Republic of China with its legal address at No.1, Ertiao, Bai Guang Road, Xuan Wu District, Beijing 100761, P. R. China, do hereby appoint and authorize **Mr. Shen Decai, Director of Sinohydro**, as my true and lawful Representative of **Sinohydro**, to conduct all and any matters in respect of pursuing & operating businesses, signing documents, contracts, agreements and opening & controlling bank accounts in relating with the **Kamchay Hydroelectric BOT Project** of Cambodia.

I hereby confirm and admit full responsibilities for and caused to be done by **Mr. Shen Decai**.

This **Power of Attorney** is effective from the issuing date and shall remain valid until the further notice.

Thereunder are the signatures of the authorized Representative and the authorizing Chairman of the Board of **Sinohydro**.

Authorized by:

Mr. Liu Qitao
Chairman of the Board
Sinohydro Corporation Ltd.

To be Authorized:

Mr. Shen Decai
Director
Sinohydro Corporation Ltd.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើត គណៈកម្មាធិការជាតិ លើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

* * *

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន

-បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

-បានឃើញអនុក្រឹត្យលេខ១៣អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ

- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

សម្រេច

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ការបង្កើតគណៈកម្មាធិការជាតិ ដើម្បីលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ហៅកាត់ថា **គ.ជ.ស.ស.ខ** ក្នុងគោលបំណងថែរក្សា ការពារវប្បធម៌ជាតិ ធានាដល់ការគោរព សីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ ដោយលើកកម្ពស់ស្ថានភាព តួនាទី សុខុមាលភាពស្ត្រីខ្មែរ ។

មាត្រា ២.-

គ.ជ.ស.ស.ខ មានសមាសភាពដូចតទៅ ÷

១. លោកជំទាវ ភរិយាសម្តេចនាយករដ្ឋមន្ត្រី	ប្រធានកិត្តិយស
២. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី	ប្រធាន
៣. រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី	១រូប អនុប្រធានអចិន្ត្រៃយ៍
៤. រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	១រូប អនុប្រធាន
៥. រដ្ឋលេខាធិការ ក្រសួងព័ត៌មាន	១រូប អនុប្រធាន
៦. រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	១រូប អនុប្រធាន
៧. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	១រូប សមាជិក
៨. អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌	១រូប សមាជិក
៩. អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	១រូប សមាជិក
១០. អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	១រូប សមាជិក
១១. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	១រូប សមាជិក
១២. អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	១រូប សមាជិក
១៣. អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	១រូប សមាជិក
១៤. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	១រូប សមាជិក
១៥. អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	១រូប សមាជិក
១៦.អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី	១រូប សមាជិក
១៧.អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា	១រូប សមាជិក
១៨.តំណាងអគ្គស្នងការនគរបាលជាតិ	១រូប សមាជិក
១៩.តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស	១រូប សមាជិក

២០.អភិបាលរាជធានីភ្នំពេញ សមាជិក

ការតែងតាំងសមាសភាព **គ.ជ.ស.ស.ខ** ខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣.-

គ.ជ.ស.ស.ខ មានភារកិច្ចដូចតទៅ ÷

១- តាមដានណែនាំ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០សសរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើស ភាពយន្ត និង វីដេអូ និង សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៤សសរ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបការធ្វើអាជីវកម្ម បញ្ចាំង និង លក់កាសែ្សតវីដេអូអាសអាភាស ។

២- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័ ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលានូវរាល់ការផ្សព្វផ្សាយ រូបភាពអាសអាភាស តាមគ្រប់មធ្យោបាយ ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម និងតម្លៃស្ត្រីខ្មែរ ។

៣- ផ្តួចផ្តើមបង្កើតយុទ្ធសាស្ត្រ សម្រាប់អនុវត្តប្រឆាំងវប្បធម៌ហិង្សាក្នុងសង្គម និងសង្គមអសីលធម៌ ដែលនាំឱ្យប៉ះពាល់ដល់សុភមង្គលក្នុងគ្រួសារ ដោយជំរុញឱ្យស្ត្រីធ្លាក់ក្នុងភាពងាយរងគ្រោះ ។

៤- តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការហូរចូល នូវវប្បធម៌អសកម្ម វប្បធម៌ហិង្សាពីបរទេស ដែលនិយមយកស្ត្រីខ្មែរជាទំនិញ ជាឧបករណ៍កំសាន្ត ជាឧបករណ៍ផ្សព្វផ្សាយពាណិជ្ជកម្ម នាំឱ្យប៉ះពាល់ដល់ភាពថ្លៃថ្នូរ តម្លៃ និងកិត្តិយសរបស់ស្ត្រីខ្មែរ ។

៥- សហការជាមួយស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព ដល់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពីផលប៉ះពាល់អវិជ្ជមាន នៃការទស្សនា និងការផ្សព្វផ្សាយរូបភាពអាសអាភាស ។

៦- បង្កើតកម្មវិធី យុទ្ធនាការផ្សព្វផ្សាយអប់រំ ដល់យុវវ័យ កុមារា កុមារី ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ ការពារវប្បធម៌ប្រពៃណីខ្មែរ និងតម្លៃសីលធម៌សង្គម ។

៧- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស រវាងស្ថាប័នរដ្ឋ និងវិស័យឯកជន ហើយធ្វើរបាយការណ៍លើកអនុសាសន៍ជូនរាជរដ្ឋាភិបាល ។

៨- រៀបចំសន្និបាតប្រចាំឆ្នាំក្រោមអធិបតីភាព លោកជំទាវកិរិយាសម្តេចនាយករដ្ឋមន្ត្រី ប្រធានកិត្តិយស **គ.ជ.ស.ស.ខ** ដើម្បីបូកសរុបលទ្ធផលកន្លងមក និង លើកផែនការអនុវត្តបន្ត ។

មាត្រា ៤.-

សមាជិក **គ.ជ.ស.ស.ខ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធានគណៈកម្មាធិការជាតិ ។ ក្នុងករណីចាំបាច់ **គ.ជ.ស.ស.ខ** អាចអញ្ជើញតំណាងស្ថាប័នជាតិផ្សេងទៀត ស្ថាប័នឯកជន និង តំណាងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធចូលរួមប្រជុំ ។

មាត្រា ៥.-

គ.ជ.ស.ស.ខ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំនៅក្រសួងកិច្ចការនារី ដោយប្រើប្រាស់មន្ត្រីមានក្របខ័ណ្ឌស្រាប់ ដើម្បីជាជំនួយការក្នុងកិច្ចសហការសម្របសម្រួលការងារដែលពាក់ព័ន្ធនឹងបញ្ហាលើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ ។ តួនាទីភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ស.ស.ខ** ។ គណៈកម្មាធិការជាតិនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ។

មាត្រា ៦.-

គ.ជ.ស.ស.ខ អាចបង្កើតអនុគណៈកម្មាធិការជំនាញអន្តរក្រសួងមួយចំនួន តាមការចាំបាច់ ជាជំនួយការ ក្នុងកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។ ការតែងតាំងសមាសភាព តួនាទី និង ភារកិច្ចរបស់អនុគណៈកម្មាធិការជំនាញអន្តរក្រសួងនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ៧.-

គ.ជ.ស.ស.ខ ត្រូវបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ជាអង្គភាពប្រតិបត្តិការផ្ទាល់នៅមូលដ្ឋាន ក្នុងកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។ គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ដឹកនាំដោយអភិបាល ឬអភិបាលរងខេត្តក្រុង និងសមាជិកមកពីមន្ទីរពាក់ព័ន្ធ ដូចក្នុងមាត្រា២ នៃអនុក្រឹត្យនេះ លើកលែងតែស្ថាប័នណា ដែលមិនមានអង្គភាពចំណុះនៅតាមបណ្តាខេត្តក្រុង ។

ការកំណត់សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.ស.ខ** ។ គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តក្រុង ។

មាត្រា ៨.-

គ.ជ.ស.ស.ខ មានថវិកាផ្ទាល់ខ្លួន ដែលជាថវិកាពិសេសរបស់រាជរដ្ឋាភិបាល ឬ ថវិកាជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយ និងសប្បុរសជនជាតិ ឬ អន្តរជាតិ ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ដូចចែងក្នុងមាត្រា២ខាងលើ មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

អ៊ឹង កន្ថាផាវី

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី

- អគ្គលេខាធិការរាជរដ្ឋាភិបាល

-គ្រប់សាលាខេត្តក្រុង

- រាជកិច្ច

-ដូចមាត្រា១០

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧៦...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាឆាន់ ០១ខ្នង អគារសិក្សា ០១ខ្នង អណ្តូងស្នប់១៨ និងទិញម៉ាស៊ីនភ្លើង នៅវត្តនទីវ័ន្ត ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ និងនៅឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

១-**អង្គការ លូធើរ៉ាន បំរើពិភពលោក** (LWF) ថវិកា ចំនួន ២៣.៩៨០ ដុល្លារ

២-លោក **សេខ ស៊ិន្តារ** អ្នកសំរបសំរួលគំរោងអភិវឌ្ឍន៍ជនបទចំរុះ អង្គការលូថើរ៉ាន បំរើពិភពលោក (LWF) ប្រចាំស្រុកទឹកផុស បានចំណាយអស់ថវិកា ចំនួន ២១.១៥០ ដុល្លារ

៣-លោក **លឹម ហុងលី** និង អ្នកស្រី **ស៊ឹម គេងគី** សប្បុរសជនខ្មែរ រស់នៅប្រទេសអូស្ត្រាលី បានចំណាយអស់ថវិកា ចំនួន ១១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៥.៣៧.០....អនក្រ.បក -៩៩

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងព្រះវិហារវត្តកុលម្ពីន អគារសិក្សា ០២ខ្នង បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ នៅឃុំច្រេស ស្រុកកំពង់ត្រឡាច និង ឃុំស្វាយរំពារ ស្រុកកំពង់លែង និងសាលាពុទ្ធិកបឋមសិក្សា ០១ខ្នង នៅ វត្តព្រះទ្វារ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោក **ម៉ាម៉ូរ៉ូ ហាយ៉ាស៊ី** (**MAMORU HAYASHI**) ប្រធានជីប៉ាកព្រីហ៊ិចឌីវេឡាយអិនក្លិប បានចំណាយអស់ ថវិកា ចំនួន ២០.០០០ ដុល្លារ

២-លោកស្រី **យ៉ាយ៉ុយ ម៉ាតស៊ូសាវ៉ា** (**YAYOI MATSUZAWA**) ប្រធានហ៊្វូណោបាសីឡាយអិនក្លិប បានចំណាយអស់ ថវិកា ចំនួន ២០.០០០ ដុល្លារ

៣-លោក **ស្រី ឡាញ់** និងអ្នកស្រី **សុត ញ៉ុល** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ ថវិកា ចំនួន ៣០.៥០០ ដុល្លារ

៤-លោក **ឈុន សារ៉េត** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១០.២០០ ដុល្លារ

៥-លោក **វ៉ាតាណាបេ មិគិ** (**WATA NABE MIKI**) សប្បុរសជនមកពីអង្គការ **SCHOOL AID JAPAN** បានចំណាយអស់ ថវិកា ចំនួន ១៣.៥០០ ដុល្លារ

៦-លោក **ហ្ស៊ី អ៊ីន ហួយ** (**JI INN HOUY**) សប្បុរសជនមកពីអង្គការ **SCHOOL AID JAPAN** បានចំណាយអស់ ថវិកា ចំនួន ១៣.៥០០ ដុល្លារ

ខ-មេដាយសេរីវឌ្ឍស្ថានាជាតិ :

១-ឧបាសិកា **ឆេព យ៉ុំ** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.២០០ ដុល្លារ

២-ឧបាសិកា **ចាន់ នី** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.៧៤៩ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.....៥៧៦.....អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមកសាង ព្រះវិហារ សាលាឆាន់ សាលាបាលី កុដិ និងសមិទ្ធផលផ្សេងៗទៀត នៅក្នុងខេត្តស្វាយរៀង ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **មួន សារិទ្ធិ** ចៅអធិការ បានចូលរួមជួយកសាងសមិទ្ធផល នៅ *វត្តទួលសុក្រម* ឃុំត្រពាំងស្ដៅ ស្រុករមាសហែក បច្ច័យ ចំនួន ១២.០០០ ដុល្លារ ។

២-ព្រះតេជគុណ **ជួន ម៉ាន់ធន់** ចៅអធិការ បានចូលរួមជួយកសាងសមិទ្ធផល នៅ *វត្តសុវណ្ណារាម* ឃុំច្រកម្ទេស ស្រុកស្វាយទាប បច្ច័យ ចំនួន ១២.០០០ ដុល្លារ ។

៣-លោក **សុខ សុខា** ប្រធានក្រុមហ៊ុន *សុខ សុខា ភ្នំពេញ* ជួយកសាងសមិទ្ធផល នៅ *វត្តឧត្តមសេរី* ឃុំគគីសោម ស្រុកស្វាយទាប ថវិកា ចំនួន ១៦.១០០ ដុល្លារ ។

ខ. មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **គង់ ណារ៉ុង** ជួយកសាងជងទង់ នៅ*វត្តឧត្តមសេរី* ថវិកា ចំនួន ៣.៥០០ ដុល្លារ

២-លោក **ញឹក ផន** កសាងព្រះវិហារ នៅ*វត្តឧត្តមសេរី* ថវិកា ចំនួន ១.៥០០ ដុល្លារ

៣-លោក **ជាំ រតនា** កសាងរោងម៉ាស៊ីនភ្លើង និងអណ្តូងទឹក នៅ*វត្តឧត្តមសេរី* ថវិកា ចំនួន ១.៣៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **អាប់ឌើរ សាម៉ាត់ពិនអាដាំ** សប្បុរសជនឥស្លាម រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារឥស្លាម ចំនួន ០២ខ្នង ០១ខ្នង នៅក្នុងឃុំកណ្តៀង ស្រុកកណ្តៀង និង ០១ខ្នងទៀត នៅក្នុងឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ចំណាយអស់ថវិកាសរុប ចំនួន ១៦.៩១២ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង កុដិ ០១ខ្នង បណ្ណាល័យ អគារសិក្សា និងជួសជុលស្ពាន ០១កន្លែង ព្រមទាំងបានឧបត្ថម្ភថវិកា ដល់កម្មវិធីសិលា សំរាប់ឃុំស្វាយចេក ឃុំតាបែន ស្រុកស្វាយចេក ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ និងនៅឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក	**ឌិត្យ លេក**	នៅខេត្តបន្ទាយមានជ័យ	ថវិកា ចំនួន ១២.៥៧០ ដុល្លារ
២-លោកស្រី	**លី ម៉ារី**	នៅខេត្តបន្ទាយមានជ័យ	ថវិកា ចំនួន ១០.០០០ ដុល្លារ
៣-លោក	**លី ស៊ាងហេង**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១០.០០០ ដុល្លារ
៤-លោកស្រី	**នួន សួនី**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១០.០០០ ដុល្លារ
៥-លោកស្រី	**លី ស៊ីណា**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ១៣.៩៤៥ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ០១ខ្នង មាន០៤បន្ទប់ ជួសជុលផ្លូវ ស្ពាន និងកសាងបុណ្យសភាសាលា ចំនួន០១ខ្នង នៅ *វត្តធម្មនិមិត្តជម្ពូជល* ឃុំស្វាយចេក ស្រុកស្វាយចេក និង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម	**ហេង ចាន់ថា**	អភិបាលខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១០.៨៤០ ដុល្លារ
២-លោក	**ញ៉េប ម៉ុនឌីន**	សប្បុរសជន	ថវិកាចំនួន ២៣.០០០ ដុល្លារ
៣-លោក	**តូ ធានធី**	សប្បុរសជន	ថវិកាចំនួន ១៦.៥០០ ដុល្លារ
៤-លោកស្រី	**ញ៉ាំ សារឿន**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១០.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ ប្រាត់ ចាំ អត្តលេខ ០៤៥៧
២- លោកវរសេនីយ៍ទោ សាន់ សំអាត អត្តលេខ ០៤៥៨
៣- លោកវរសេនីយ៍ទោ សុខ ចាន់ដន អត្តលេខ ០៤៥៩
៤- លោកវរសេនីយ៍ទោ ឡុត ចំរើន អត្តលេខ ០៤៦០
៥- លោកវរសេនីយ៍ទោ ឌឹម សារឿន អត្តលេខ ០១៣៧៩
៦- លោកវរសេនីយ៍ទោ ស៊ី ឧត្តម អត្តលេខ ០២១៨៦
៧- លោកវរសេនីយ៍ទោ ឈៀម សុខន អត្តលេខ ០៧០៣១
៨- លោកវរសេនីយ៍ទោ តោន ណារ៉ា អត្តលេខ ០២១៤១
៩- លោកវរសេនីយ៍ទោ គីម អ៊ាង អត្តលេខ ០២១៤២
១០- លោកវរសេនីយ៍ទោ ទៅ សុធី អត្តលេខ ០២៣២៩ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតថេរសភានៃព្រះពុទ្ធសាសនា
នៅព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ ចុះថ្ងៃទី១៥/០៧/២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០/០៧/១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញ សង្ឃប្រកាសលេខ ៣៣.កសរ.វ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់ ករណីកិច្ចនៃចៅអធិការ អនុគណ មេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៦២ បានសំរេចហើយនោះទុកជាករណីកិច្ចថេរមាន ដើម្បីបន្តអនុវត្តសម្រាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនាតទៅ ។

-បានឃើញ ដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងការកើតឡើងនូវអធិករណ៍ជាបន្តបន្ទាប់ នៅក្នុងជួរនៃអ្នកបួសក្នុងព្រះពុទ្ធសាសនា រវាងព្រះសង្ឃនិងព្រះសង្ឃ រវាងព្រះសង្ឃនិងគ្រហស្ថជាបុគ្គល ឬជាសមូហភាព ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ដល់ព្រះពុទ្ធសាសនា ជាសាសនារបស់ជាតិ ។

-យោងតាមស្មារតីអង្គប្រជុំថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

-តាមសំណូមពរ របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា.

ស ម្រេ ច

<u>មាត្រា</u> ១-បង្កើតថេរសភានៃព្រះពុទ្ធសាសនាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការកំពូល សម្រាប់ដោះស្រាយអធិករណ៍នៃពុទ្ធសាសនា ដែលមានសមាសភាពដូចខាងក្រោមនេះ :

១-	សម្តេចព្រះធម្មលិខិត	**លាស់ ឡាយ**	ប្រធាន
២-	សម្តេចព្រះឧត្តមមុនី	**ហេង លាងហោ**	អនុប្រធានទី ១

៣-	សម្តេចព្រះវន្ន័ត	ណយ ច្រឹក	អនុប្រធានទី ២
៤-	សម្តេចព្រះពោធិវង្ស	អំ លីមហេង	អនុប្រធានទី ៣
៥-	សម្តេចព្រះឧត្តមវង្សា	មួង រ៉ា	លេខាធិការ
៦-	សម្តេចព្រះឧត្តមបញ្ញា	ជួង ផង់	សមាជិក
៧-	សម្តេចព្រះឧត្តមចរិយា	ឈឹង ប៊ុនឈា	សមាជិក
៨-	ព្រះមុនីកោសល	ហ៊ិល សុវណ្ណ	សមាជិក
៩-	ព្រះសិរីសម្មតិវង្ស	យ៉ឿង យ៉ាត	សមាជិក

មាត្រា ២-ថេរសភានៃព្រះពុទ្ធសាសនាមានភារកិច្ចដូចតទៅនេះ :

-ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះមហាសុមេធាធិបតី ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃ ដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

-ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃ និងសង្ឃ. រវាងសង្ឃ និងគ្រហស្ថ ដែលវិនយធរ ធម្មធរ អនុគណ មេគណ សង្ឃនាយក ឬ សង្ឃរាជ ពុំអាចរំងាប់បាន ។

-ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន ។

-រកគ្របវិធីធ្វើការណែនាំ សម្រុះសម្រួល នូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាពសិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល ។

-ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសំរេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស ។

-ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង ៤ ។

-ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះមហាសុមេធាធិបតី តម្រូវឱ្យជួយដោះស្រាយ ។

មាត្រា ៣-ថេរសភានៃព្រះពុទ្ធសាសនា ត្រូវរៀបចំលេខាធិការដ្ឋានមួយ ដឹកនាំដោយសម្តេចព្រះឧត្តមវង្សា មួង រ៉ា និងមានសមាជិកមួយចំនួន ជាជំនួយការ ។

មាត្រា ៤-ថេរសភានៃព្រះពុទ្ធសាសនា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក សំរាប់ដំណើរការ ។

មាត្រា ៥-រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងសមាសភាពដូចក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ។

មាត្រា ៦-បទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧-អនុក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៥៧៣.....អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់នៃគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការសម្របសម្រួលនៃដំណើរការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ និង ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :

- ឯកឧត្តម **យឹម ឈុលឡា** ប្រធានគណៈកម្មការ

ខ-មេដាយសុវត្ថារា ថ្នាក់ សេនា :

១-ឯកឧត្តម **អ៊ឹក សូមេត្ត** អគ្គនាយករង អាជ្ញាធរអប្សរា

២-ឯកឧត្តម **ម៉ម សុផាន់ណា** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣-ឯកឧត្តម **នា សុថ្ងា** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

៤-លោក **ជែម សុវិជ្ជារនា** អគ្គនាយករង ក្រសួងសាធារណការ និងដឹកជញ្ជូន

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូន លោក **Vincent PIRON** អនុប្រធានក្រុមហ៊ុន SCA ដែលមានស្នាដៃល្អក្នុងការស្ថាបនាអាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ និងខេត្តសៀមរាប ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៥៧៩...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់សមាជិកជ្រើសតាំង
សម្រាប់សភាពាណិជ្ជកម្មខេត្តកណ្តាល អាណត្តិទី១ លើកទី១

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០៦៩៥/ ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/ រកម /០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំ ការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលាឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកណ្តាល
- បានឃើញកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកណ្តាល អាណត្តិទី១ ថ្ងៃទី ២៨ ខែ ឧសភា ២០០៦ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្មខេត្តកណ្តាល
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១ : ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកណ្តាល ចំនួន ១៥ រូប ដូចខាងក្រោម :

១-	ឧកញ៉ា	**យ៉ែម**	**គុសល**
២-	លោកស្រី	**ម៉ុន**	**ឌី**
៣-	លោក	**ឌី**	**លីហាន**
៤-	ឧកញ៉ា	**ឡូច**	**ហ៊ុន**
៥-	លោក	**កន**	**សុវណ្ណ**
៦-	លោកស្រី	**គីម**	**សុភាព**
៧-	លោក	**ម៉ែន**	**ស្រ៊ុន**
៨-	លោកស្រី	**តិច**	**អេន**
៩-	លោកស្រី	**សុខ**	**លីម**
១០-	លោកស្រី	**ម៉ម**	**គៀង**
១១-	លោកស្រី	**ឈុន**	**ហ៊ុយ**
១២-	លោកស្រី	**ទឡ្យ**	**ស្រីនុច**
១៣-	លោកស្រីឧកញ៉ា	**សៀង**	**ចាន់ហេន**
១៤-	លោកស្រី	**ហេន**	**ស៊ីវខេន**
១៥-	លោកស្រី	**គីន**	**គន្ធា**

មាត្រា ២ : ទទួលស្គាល់ឧកញ៉ា **យ៉ែម គុសល** ជាប្រធានសភាពាណិជ្ជកម្មខេត្តកណ្តាល ។

មាត្រា ៣ : បទប្បញ្ញត្តិ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ពន្ធ័ អភិបាលខេត្តកណ្តាល ប្រធានសភា -ពាណិជ្ជកម្មខេត្តកណ្តាល និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ និង មាត្រា២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មខេត្តតាកែវ អាណត្តិទី១ លើកទី១

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស / រកម /០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំ ការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលាឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តតាកែវ
- បានឃើញកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តតាកែវ អាណត្តិទី១ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៦ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្មខេត្តតាកែវ
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តតាកែវ ចំនួន ១៥ រូប ដូចខាងក្រោម :

១- ជំទាវឧកញ៉ា **កែវ ម៉ាលី**
២- លោកស្រី **ឈឹម សារឿន**
៣- លោក **លីវ គីមជីវ**
៤- លោកស្រី **ម៉ែត មុំយ**
៥- លោក **អ៊ុង ជាតុក**
៦- លោក **ឆាន អ៊េង**
៧- លោក **លី អ៊ុំលាង**
៨- លោក **ខន ញៀប**
៩- លោក **ឡើវ ម៉េងសៀង**
១០- លោកស្រី **សុខ សារឿន**
១១- លោក **ជា គីង**
១២- លោក **លីម ហួត**
១៣- លោក **ជុំ វណ្ណា**
១៤- លោកស្រី **សៅ ណៃហ៊ង**
១៥- លោក **ហ៊ុន សារុំ**

មាត្រា ២ : ទទួលស្គាល់ជំទាវឧកញ៉ា **កែវ ម៉ាលី** ជាប្រធានសភាពាណិជ្ជកម្មខេត្តតាកែវ ។

មាត្រា ៣ : ទទួលស្គាល់ការបង្កើតការិយាល័យប្រតិបត្តិមួយ របស់សភាពាណិជ្ជកម្មខេត្តតាកែវ ដែលមានសមាសភាព ដូចខាងក្រោម :

១- ជំទាវឧកញ៉ា **កែវ ម៉ាលី** ជាប្រធាន
២- លោក **អ៊ុង ជាតុក** ជាអនុប្រធាន
៣-លោក **លីម ហួត** ជាអនុប្រធាន
៤- លោក **លីវ គីមជីវ** ជាហិរញ្ញិក
៥- លោក **ហ៊ុន សារុំ** ជាហិរញ្ញិក
៦-លោក **ឡើវ ម៉េងសៀង** ជាលេខាធិការ
៧-លោក **ឆាន អ៊េង** ជាលេខាធិការ

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តតាកែវ ប្រធានសភា-ពាណិជ្ជកម្មខេត្តតាកែវ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ មាត្រា២ និង មាត្រា៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០០១/០៦ ម.ស.រ.ស.ព

ព្រះសង្ឃប្រកាស
ស្តីពី
ការកំណត់បែងចែកភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា
និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/២០០ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ ស្តីពីការតែងតាំង ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជ គណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ឱ្យឡើងព្រះឋានៈ ជាសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើត គណៈសង្ឃនាយក ដោយតម្លើងសម្តេចព្រះពោធិវង្ស នន្ទ ង៉ែត ឱ្យឡើងព្រះឋានៈជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា,
- យោងតាមស្មារតីអង្គប្រជុំ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៦ ស្តីពីដំណើរការប្រព្រឹត្តទៅ នៃវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា,
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

ស ម្រេ ច

ប្រការ ១- កំណត់បែងចែកព្រះភារកិច្ចថ្វាយ-ប្រគេន សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅនេះ :

ក/ព្រះរាជភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី :

ក-១- ទទួលគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនាក្នុងប្រទេស និងទំនាក់ទំនងការងារពុទ្ធសាសនានៅក្រៅប្រទេស ឱ្យប្រព្រឹត្ត ទៅប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ។

ក-២- ទទួលភារកិច្ចចុះព្រះហស្តលេខា លើប្រកាសនីយបត្រតែងតាំងព្រះសមុហ៍គណ ព្រះធម្មធរគណ ព្រះវិន័យធរគណ ព្រះបាឡាត់គណ ព្រះអនុគណ និងព្រះមេគណឡើងទៅ តាមបែបបទពីមូលដ្ឋាន និងតាមសំណើរបស់គណៈសង្ឃនាយក ដោយមានការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក-៣- រាល់ការតែងតាំងតម្លើង ឬដកឋានៈគោរម្យងារ ជាទីប្រឹក្សា, ជារាជាគណៈកិត្តិយស, ជារាជាគណៈក្នុងងារ ឋានានុក្រម និងមុខងារផ្សេងៗ ពាក់ព័ន្ធដល់ព្រះរាជក្រឹត្យ ត្រូវធ្វើតាមសំណើរពីគណៈសង្ឃនាយក និងការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។/.

ខ/ព្រះភារកិច្ចរបស់សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

ខ-១- ទទួលភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។

ខ-២- ចុះព្រះហស្តលេខា លើប្រកាសនីយបត្រ តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ព្រះវិន័យធរ លេខាធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើរបស់សមូហភាពសង្ឃនៃវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះបាឡាត់គណ ព្រះមេគណ ដោយមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង តាមរយៈក្រសួងធម្មការនិងសាសនា ដោយត្រូវរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជទ្រង់ជ្រាប ។

ខ-៣- ទទួលព្រះភារកិច្ច ក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជន ស្នាក់នៅក្នុងវត្ត នៅក្នុងទូទាំងប្រទេស បូកសរុបរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ការបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខ័ណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ ។

ខ-៤- ទទួលព្រះភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា ក្នុងឋានៈជាអគ្គនាយកពុទ្ធិកសិក្សា និងជាពុទ្ធិកសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ដោយត្រូវផ្តោតព្រះទ័យទៅលើការពង្រឹងគុណភាព នៅសាលាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារៈបរិក្ខារ កម្មវិធីសិក្សា ។ល។ និងសាលាធម្មវិន័យទាំង៣ថ្នាក់ ។

ប្រការ ២- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក មានមន្ត្រីសង្ឃ និងគ្រហស្ថមួយចំនួន ជាជំនួយការតាមតម្រូវការចាំបាច់ និងប្រើប្រាស់គ្រាជាផ្លូវការ តាមកម្រិតគោរម្យងារកំណត់រៀងៗព្រះអង្គ ។

ប្រការ ៣- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកធ្វើការងារដោយសហការជិតស្និទ្ធ ក្នុងជំហរសាមគ្គីភាព ជាសហធម្មិកតាមភារកិច្ច ដែលបានកំណត់ឱ្យប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អប្រសើរ ។

ប្រការ ៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមព្រះសង្ឃប្រកាសនេះ ។

ប្រការ ៥- បទប្បញ្ញត្តិទាំងឡាយណា ផ្ទុយពីព្រះសង្ឃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦- ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព និងស្ថេរភាពចាប់ពីថ្ងៃចុះព្រះហស្តលេខា និងហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ព.ស ២៥៥០
គ.ស ២០០៦

លេខ : ០១ (ព្រ.ក)

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី២៤ខែ [illegible] ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក

នន្ទ ង៉ែត

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី
សម្តេចព្រះមហាសង្ឃរាជ

ទេព វង្ស

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ....០១..បប....

ភ្នំពេញ,ថ្ងៃទី....១៨.....ខែ ឧសភា ឆ្នាំ២០០៦

បទបញ្ជា

ស្តីពី

ការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ

ក្នុងគោលបំណង ថែរក្សាការពារនិងពង្រឹងយ៉ាងម៉ឺងម៉ាត់នូវការគ្រប់គ្រងដីព្រៃឈើគ្រប់ប្រភេទ ពីការកាប់បំផ្លាញ ទន្ទ្រាន និង ហ៊ុំព័ទ្ធយកធ្វើជាកម្មសិទ្ធ **រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវបទបញ្ជាជាបន្ទាន់ ឱ្យអភិបាលខេត្ត-ក្រុង អនុវត្តដូចខាងក្រោម៖**

១- ត្រូវប្រើប្រាស់អំណាចរដ្ឋ ដោយចេញដីកាជាបន្ទាន់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៦ ដោយប្រកាសបដិសេធ និងដកហូតដីព្រៃឈើគ្រប់ប្រភេទ ដែលត្រូវបានរំលោភបំពានទាំងអស់មកទុកជាសម្បត្តិរដ្ឋវិញតាមការចាំបាច់។

២- ដីកានេះត្រូវកំណត់រយៈពេល ៣០ ថ្ងៃ ដើម្បីឱ្យគេធ្វើការប្តឹងតវ៉ា ហើយក្នុងករណីមិនមានអ្នកប្តឹងទាមទារទេនោះ អភិបាលខេត្ត-ក្រុង ត្រូវរាយការណ៍ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយនិងហ៊ុំព័ទ្ធដីព្រៃឈើរាតយកដីធ្វើកម្មសិទ្ធិ ដើម្បីរាជរដ្ឋាភិបាល ចេញអនុក្រឹត្យកំណត់ទុកដីទាំងនោះជាសម្បត្តិរដ្ឋ។

៣- ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងដីព្រៃឈើគ្រប់ប្រភេទ ដែលមានជាធរមាន ឱ្យបាន ត្រឹមត្រូវនិងម៉ឺងម៉ាត់បំផុត ជាពិសេសអំពីទោសប្បញ្ញត្តិចំពោះជនទាំងឡាយណាដែលបានរំលោភបំពានលើដីព្រៃ ឈើគ្រប់ប្រភេទ យកធ្វើជាកម្មសិទ្ធិនោះ។

៤- ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការ ដ្ឋាននគរបាលជាតិ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវសហការអនុវត្តបទបញ្ជានេះ ក្នុងស្មារតីទទួលខុសត្រូវ និង ឱ្យមានប្រសិទ្ធិភាពខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការ ជាតិដើម្បីទប់ស្កាត់ លុបបំបាត់និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើរាតយកដីធ្វើកម្មសិទ្ធិ តាមករណីជាក់ស្តែងនិមួយៗ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អគ្គលេខាធិការដ្ឋានប្រតិបត្តិ គជដក
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចចំណុចទី ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤៦ ពណ.ចភក

ភ្នំពេញថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ី សេង ខូ អិលធីឌី**
Y SENG CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8824/06P** ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **យឹម អេងគាត** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ឌីង សាំងគាច** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៨៦ DEo ផ្លូវលេខ ៦៣ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថុល

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤៧ ពណ.នតក

ភ្នំពេញថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេគ្រីខន គ្រុប**
AGRICON GROUP Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8825/06P ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
លោក **កែ ផៃ** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ខ្វិ ហ៊ុងសេង** អភិបាល
លោក **អ៊ុច សុខហេង** អភិបាល
លោក **អ៊ុច ចណ្ណា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២១ ផ្លូវជាតិលេខ៦ ភូមិបល្ល័ង្កលិច ឃុំដីជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនទាំងក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
កឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តកំពង់ធំ
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤០ ពណ.នតក

ភ្នំពេញថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ថៃយ៉ូ (ខេមបូឌា)**

TAIYO (CAMBODIA) Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2997/06E ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក MASAKAZU KITAGUCHI ប្រធានក្រុមប្រឹក្សាភិបាល

លោក TAKEHITO KITAGUCHI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : សណ្ឋាគារកាំបូឌីយ៉ាណា លេខ ៣១៣ វិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -សេវាផ្នែកពត៌មានវិទ្យា-អ៊ិនធើណេត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលសំភារៈបរិក្ខារអគ្គីសនី អេឡិចត្រូនិច កុំព្យូទ័រ និងគ្រឿងបន្លាស់ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

ចាម ប្រសិទ្ធ

គីម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៦៥១ ពណ.នគក

ភ្នំពេញថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៦

នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **មិក គ្រុប ខូ អិលធីឌី**
MIG GROUP Co., Ltd.
